គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)

Committee For Free And Fair Elections In Cambodia (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

ខុមហ្វ្រែល COMFRE P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

គណៈកម្មាធិការនាយក
BOARD OF DIRECTORS

លោក ធន សារាយ
Mr. THUN SARAY
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន ADHOC

លោក សុក សំអឿន
Mr. SOK Sam Oeun
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក CDP

លោក យឹម ប៉ូ
Mr. YIM Po អគ្គហេរញ្ញិក
និង នាយក CCPCR

កញ្ញា ស៊ុន ចាន់សែន
Miss. SUN Chansen
ប្រធាន KYA

លោក មុំ សារិន
Mr. MOM Sarin
នាយក HRCDO

លោកស្រី ពឹង យក់ហៀប
Ms. PEUNG Yok Hiep

លោកស្រី ទិវ សារាយេត
Ms. TIV Sarayet
សហនាយិកា WMC

កញ្ញា សយ សារា វឌ្ឍនី
Miss. SAY Sara Vathany
នាយិកា CWCC

លោក គឹម សុវណ្ណ
Mr. KIM Sovann
នាយក VIGILANCE

លោក អាង ច័ន្ទឫទ្ធិ
Mr. ANG Chanrith
នាយក KKKHRO

លោក យង់ គិមអេង
Mr. YONG Kim Eng
នាយក PDP-Center

លោក ភួង សិទ្ធិ
Mr. PHUONG Sith

លោក ស៊ីន សែត
Mr. SEN Set

ស.ប្រ.ក.៣/លេខ ០៦/០៩ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាពក្នុង ខេត្ត មណ្ឌលគិរី

*ភ្នំពេញ, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៩*

ប្រជាពលរដ្ឋប្រមាណ៨០នាក់ មកពីស្រុកកែវសីម៉ា ស្រុកកោះញែក ស្រុកពេជ្រាដា ស្រុកអូររាំង និងក្រុងសែនមនោរម្យក្នុងខេត្តមណ្ឌលគិរី ដោយមានសិក្ខាកាមស្ត្រីចូលរួមប្រមាណ៣៦% បានជួបជុំគ្នានៅក្នុងសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តមណ្ឌលគិរី កាលពីចុងខែឧសភា។

អភិបាលរងខេត្តមណ្ឌលគិរី ឯកឧត្តម ហេង សំណាង បានថ្លែងបើកសិក្ខាសាលា ដោយឯកឧត្តមបានមានប្រសាសន៍ថា កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ សឹងតែគ្រប់ដណ្តប់លើគ្រប់វិស័យ ហើយឯកឧត្តមក៏សង្ឃឹមយ៉ាងមុតមាំថា សិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តមណ្ឌលគិរីនេះ ក៏ជាការរួមចំណែករបស់សង្គមស៊ីវិលតាមវិធីមួយបែបទៀតដើម្បីផ្សារភ្ជាប់ពីតម្រូវការរបស់ប្រជាពលរដ្ឋក្នុងមណ្ឌលនៃខេត្តនេះទៅឱ្យមន្ត្រីជាប់ឆ្នោត។

ជាលទ្ធផល ម្ចាស់ឆ្នោតបានពិភាក្សាកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តមណ្ឌលគិរីដូចខាងក្រោម៖

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអទិភាពទាំងដប់នៅក្នុងខេត្ត មណ្ឌលគិរី** |
|---|
| ១) សុំឱ្យរាជរដ្ឋាភិបាលផ្តល់ពូជស្រូវ( ផ្កាខ្ញី ផ្កាដូង សែនពិដោរ )នៅស្រុកអូររាំង ស្រុកកែវសីម៉ា ស្រុកកោះញែក ស្រុកពេជ្រាដា និងក្រុងសែនមនោរម្យឱ្យបានមួយគ្រួសារ៥០ គីឡូក្រាម គ្រប់គ្រួសារឱ្យបាននៅឆ្នាំ ២០១០។ |
| ២) សុំឱ្យរាជរដ្ឋាភិបាលផ្តល់ដីសម្បទានសង្គមកិច្ច (ដល់ប្រជាពលរដ្ឋដែលគ្មានដី)នៅគ្រប់ស្រុកនៃខេត្តមណ្ឌលគិរី ដោយក្នុងមួយស្រុក ៥០០០ ហិកតា ចាប់ផ្តើមពី ឆ្នាំ ២០១០ ដល់ឆ្នាំ ២០១៥។ |
| ៣) សុំអណ្តូងទឹកស្អាតចំនួន ៥ អណ្តូង ក្នុងមួយភូមិ ( គ្រប់ភូមិ)ឱ្យបានគ្រប់ស្រុកក្នុងខេត្តមណ្ឌលគិរី ឱ្យបាននៅឆ្នាំ ២០១០។ |

---

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្តែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើតស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាសលាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់។

| |
|---|
| ៤) សុំធ្វើផ្លូវចំនួន ៤ ខ្សែ (ស្ពាន និង លូ)។ ១ ខ្សែក្រាលគ្រួស ក្រហមពីផ្សារកែវសីម៉ា ទៅដល់ភូមិ ការទី ឃុំស្រែព្រះ ស្រុកកែវសីម៉ា ទទឹង៨ ម៉ែត្រ ប្រវែង២៤ គីឡូម៉ែត្រ ចាប់ផ្តើមនៅឆ្នាំ២០១០ បញ្ចប់នៅឆ្នាំ២០១២។ និងផ្លូវលំ១ខ្សែ ពីភូមិស្រែព្រះ ដល់ភូមិស្រែអំពិល ទទឹង៧ម៉ែត្រ ប្រវែង៨គីឡូម៉ែត្រ ចាប់ផ្តើមពីឆ្នាំ២០១១ ដល់២០១២។ ផ្លូវ១ខ្សែក្រាលកៅស៊ូនៅភូមិដោះក្រមុំ ឃុំស្រែព្រះ ស្រុកកែវសីម៉ា ទទឹង៧ ម៉ែត្រ បណ្តោយ១000ម៉ែត្រ ចាប់ផ្តើមឆ្នាំ២០១០ បញ្ចប់ឆ្នាំ២០១១។ ផ្លូវ១ខ្សែ នៅភូមិអូរស្ពាន សង្កាត់ស្ពានមានជ័យ ទទឹង១0ម៉ែត្រ ប្រវែង១000ម៉ែត្រ ចាប់ផ្តើម ចុងឆ្នាំ ២00៩ បញ្ចប់នៅឆ្នាំ ២០១០។ |
| ៥) សុំឱ្យរាជរដ្ឋាភិបាលជួយរកទីផ្សារឱ្យផលិតផលដំឡូងមី និងផ្លែឈើ (ខ្នុរ ចេក ទាប) ដោយដំឡូងមីមួយគីឡូក្រាម ស្មើពាក់កណ្តាលនៃតំលៃ អង្ករមួយគីឡូក្រាម និងតំលៃផ្លែឈើប្រភេទ ខ្នុរ ចេក ទាប ស្មើតំលៃប្រេងសាំងមួយលីត្រ និងតំលៃផ្លែប័រ ១គីឡូក្រាម ស្មើ ២ គីឡូក្រាមតំលៃអង្ករ ចាប់ផ្តើមពីដើមឆ្នាំ២០១០។ |
| ៦) សុំរាជរដ្ឋាភិបាលបង្កើតរោងចក្រម្សៅមីចំនួន ១ នៅទីរួមខេត្ត និងសុំត្រាក់ទ័រ ចំនួន ៤ គ្រឿងនៅក្រុងសែនមនោរម្យ ឱ្យបាន នៅចុងឆ្នាំ ២០១០។ |
| ៧) ចង់ឱ្យតុលាការកាត់ក្តីឱ្យមានយុត្តធម៌ នឹងមិនមានលំអៀង(ស្របតាមនិតិវិធី) ឱ្យបាន ១00% កុំស៊ីសំណូក ជាមួយជនអ្នកមានលុយចាប់ពីចុងឆ្នាំ ២00៩។ |
| ៨) សុំឱ្យរាជរដ្ឋាភិបាលផ្តល់ពូជសត្វណាមួយក្នុងចំណោមសត្វទាំងនេះ(គោ ក្របី ជ្រូក មាន់ ទា....) នៅស្រុកអូររាំង ស្រុកកែវសីម៉ា ស្រុកពេជ្រាដា និងក្រុងសែនមនោរម្យ ដោយក្នុង១គ្រួសារ១ក្បាល គ្រប់ភូមិ យ៉ាងហោចណាស់៥0គ្រួសារក្នុង១ឆ្នាំ ចាប់ផ្តើម នៅដើមឆ្នាំ ២០១០។ |
| ៩) សុំកសាងសាលារៀនអនុវិទ្យាល័យថ្មីមួយ ដែលមានអាគារចំនួន ១ ខ្នង ៦បន្ទប់ នៅក្នុងសង្កាត់រមនា ក្រុងសែនមនោរម្យ សង់ជាថ្ម ដំបូលប្រក់ក្បឿង ចាប់ផ្តើមធ្វើនៅដើមឆ្នាំ ២០១0 បញ្ចប់នៅឆ្នាំ ២០១១។ |
| ១0) សុំបង្កើតរោងចក្រកាត់ដេរយ៉ាងហោចណាស់ចំនួន ១ សំរាប់យុវជន យុវនារីមានការងារ នៅទីរួមខេត្តមណ្ឌលគីរី ឱ្យបាននៅចុងឆ្នាំ ២០១០។ |

សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការខុមហ្វ្រែល សហការជាមួយអង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព(DPA) និងមជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍(CLEC) ដែលក្នុងនោះមានការចូលរួមពីម្ចាស់ឆ្នោតដែលតំណាងឱ្យសហគមន៍ព្រៃឈើ ដីធ្លី... និងអង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/ និស្សិត កសិករ។

សិក្ខាសាលាម្ចាស់ឆ្នោតនេះ ជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនៅតាមមណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២00៨

២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន

៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យទាំងនោះ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទង:*

- លោក **ច័ន្ទ ដារិទ្ធ** អ្នកសម្របសម្រួលផ្នែកព័ត៌មានខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១
- លោក **សុខ ពិទូរ្យ** អ្នកសម្របសម្រួលស្តីទីផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៤៦